# ប្រវត្តិព្រះពុទ្ធសាសនាក្នុងព្រះរាជាណាចក្រកម្ពុជា
## (ដោយសង្ខេប)

ពុទ្ធសករាជ៣០០ស្តេច*ចក្រពត្តិអសោកមហារាជ*បានបញ្ជូនសមណទូតពីរព្រះអង្គគឺ *ព្រះសោណៈថេរៈ* និង *ព្រះឧត្តរថេរៈ*មកផ្សព្វផ្សាយព្រះពុទ្ធសាសនានៅសុវណ្ណភូមិ ឬអាស៊ីប៉ែកអគ្នេយ៍បច្ចុប្បន្ន ។ចាប់ពីពេលនោះមកព្រះពុទ្ធសាសនាបានចាក់ឫសនៅក្នុងតំបន់នេះ ជាពិសេសរដ្ឋបុរាណសំខាន់ៗដូចជា*អាណាចក្រហ្វូណន* (ជារដ្ឋដំបូងរបស់ខ្មែរយើង) ត្រូវបានគេអះអាងថាព្រះពុទ្ធសាសនារីកចំរើនយ៉ាងខ្លាំង ។

ក្នុងចំណោមព្រះរាជាហ្វូណនទាំងអស់ *ព្រះបាទកោណ្ឌញ្ញៈជ័យវរ្ម័ន* (គ.ស.៤៧៨–៥១៤) បានបញ្ជូនសមណទូតខ្មែរទៅកាន់ប្រទេសចិន ក្រោមការដឹកនាំរបស់*ព្រះនាគសេន*ពីឥណ្ឌា ។ ស្តេចចិនដដែលនេះបានទទួលព្រះភិក្ខុសង្ឃចំនួនពីរព្រះអង្គដែលមានការសិក្សាខ្ពស់ខាងព្រះពុទ្ធសាសនាពីរប្រទេសកម្ពុជា គឺ *ព្រះសង្ឃបាលៈថេរៈ*និង *ព្រះមន្ត្រៈថេរៈ*បានធ្វើដំណើរទៅកាន់ប្រទេសចិននៅដើមសតវត្សន៍ទី៦ដើម្បីប្រែ*គម្ពីរវិមុត្តិមគ្គ*ដែលជាគម្ពីរចំណាស់ជាង*គម្ពីរវិសុទ្ធិមគ្គ*របស់ព្រះពុទ្ធឃោសាចារ្យ សព្វថ្ងៃ*គម្ពីរវិមុត្តិមគ្គ*ត្រូវបានគេបកប្រែពីភាសាចិនជាភាសាផ្សេងៗជាច្រើន ដូចជាភាសាអង់គ្លេស ។

*ព្រះបាទរុទ្រវរ្ម័ន*(គ.ស.៥១៤–៥៣៩) បានចារឹកទុកជាសិលាចារឹកថានៅក្នុងប្រទេសព្រះអង្គមានព្រះកេសាធាតុរបស់ព្រះពុទ្ធជាម្ចាស់ទុកគ្រាន់បូជា ។ ក្នុងពេលនេះព្រះពុទ្ធសាសនាបែបថេរវាទដែលប្រើភាសាសំស្រឹតរីកចំរើនយ៉ាងខ្លាំងរវាងសតវត្សន៍ទី៥ និងដើមសតវត្សន៍ទី៦ ។ រវាងសតវត្សន៍ទី៧ការប្រើភាសាបាលីដ៏មានប្រជាប្រិយភាពនៅភូមិភាគខាងត្បូង បានធ្វើអោយព្រះពុទ្ធសាសនាខ្មែរនិកាយថេរវាទមានភាពរឹងប៉ឹងខ្លាំងឡើង ។

*ព្រះបាទយសោវរ្ម័ន*(គ.ស.៨៨៩–៩០០) ជាស្តេចខ្មែរដ៏ខ្លាំងក្លាមួយព្រះអង្គបានកសាង*សង្ឃតាស្រម* ព្រមទាំងបានបដិបត្តិតបៈឬអាស្រមយ៉ាងទៀងទាត់ ។ ក្នុងពេលនោះទាំងព្រះពុទ្ធសាសនា ព្រហ្មញ្ញសាសនាវិស្ណុនិកាយឬសិវៈនិកាយ បានរីកដុះដាលក្នុងប្រទេសកម្ពុជា ។

ក្នុងរាជសម័យ *ព្រះបាទជ័យវរ្ម័នទី៥* (គ.ស.៩៦៨–១០០១)ជារាជទាយាទរបស់ *ព្រះបាទរាជេន្ទ្រវរ្ម័នទី២* បានទទួលយកព្រះពុទ្ធសាសនានិកាយមហាយានមកបដិបត្តិ ។ ព្រះមហាក្សត្របានគាំទ្រការបដិបត្តិធម៌ និងគោរពបូជាត្រីកាយព្រះពុទ្ធអង្គដោយវិធីនេះ រហូតដល់សតវត្សន៍ទី១០ ព្រះពុទ្ធសាសនានិកាយមហាយានបានអភិវឌ្ឍន៍ជាសាសនារបស់រដ្ឋ ។

*ព្រះបាទប្រាក្រាមាភាហុទី១* របស់ប្រទេសសីរីលង្កាបានលើកព្រះរាជធីតាមួយព្រះអង្គអោយដល់ *ព្រះបាទជ័យវរ្ម័នទី៧* ដែលជាព្រះរាជបុត្រារបស់ *ព្រះបាទធរណិន្ទ្រវរ្ម័នទី២* គ.ស.១១៥០–១១៦០ដែលក្រោយមកព្រះអង្គបានឡើងគ្រោងរាជជាស្តេចអស្ចារ្យ ។ ព្រះបាទជ័យវរ្ម័នទី៧ គ.ស.១១៨១–១២២០ ជាពុទ្ធមាមកៈ ហើយព្រះនាមក្រោយទីវង្គតរបស់ព្រះអង្គគឺ *មហាបរមសុគត*។ ព្រះអង្គឧបត្ថម្ភព្រះពុទ្ធសាសនានិកាយថេរវាទ តាមសិលាចារឹកបាន បង្ហាញពីទ្រឹស្តីជីវិតបែបពុទ្ធនិយមដ៏ប្រសើរជាពិសេសទាក់ទងនឹងការបរិច្ចាគ


រៀបរៀងដោយ ព្រះភិក្ខុវោទានោ សេង សុភ័ណ (បរិញ្ញាប័ត្រទស្សនវិជ្ជា)

ទានការសង្គមសង្គ្រោះ និងសកលមេត្តាចំពោះសត្វលោកទាំងមូល។ សិលាចារឹកមួយរបស់ព្រះអង្គបានប្រាប់យើងអោយដឹងពីការកសាងវត្តចំនួន៧៩៨និងមន្ទីរពេទ្យចំនួន១០២ ទូទាំងអាណាចក្រ ហើយវត្តនិងមន្ទីរពេទ្យទាំងអស់នោះបានទទួលការឧបត្ថម្ភទាំងស្រុកពីព្រះមហាក្សត្រ។

ព្រះភិក្ខុសង្ឃមួយអង្គដែលបានត្រឡប់ទៅកាន់ប្រទេសភូមាជាមួយភិក្ខុឆបតៈ គឺ*តាមលិន្ទមហាថេរៈ* ដែលគេភាគច្រើនសន្និដ្ឋានថាជាព្រះរាជបុត្រាព្រះបាទជ័យវរ្ម័នទី៧ជាមួយព្រះនាងឥន្ទ្រទេវី ដែលជាព្រះជេដ្ឋារបស់ព្រះនាងជយទេវី (ជាមួយព្រះនាងជយទេវីមានព្រះរាជបុត្រាចំនួន៣ព្រះអង្គគឺស្រិន្ទកុមារ ឥន្ទ្រកុមារ និងសុរិយកុមារ)។ ក្រោមការហូរចូលមករបស់លទ្ធិសាសនាបែបសិង្ហលៈ ធ្វើអោយបារមីភាពរបស់ព្រះមហាក្សត្រធ្លាក់ចុះ អំណាចខាងអាណាចក្រត្រូវបានគេឆក់យកចេញ និងព្រះទេវរាជាត្រូវបានគេយកចេញពីក្តារហឹង (បើតាមឯកសារពិគ្រោះភាគច្រើន)។ ព្រះពុទ្ធសាសនានិកាយថេរវាទបានក្លាយជាសាសនាចំបងគេសំរាប់ប្រជាជនខ្មែរសម័យអង្គរនាចុងរាជសម័យរបស់ព្រះបាទជ័យវរ្ម័នទី៧

នៅពាក់កណ្តាលនៃសតវត្សន៍ទី១២ កិត្តិនាមនៃព្រះពុទ្ធសាសនាថេរវាទបែបសីរីលង្កាបានឈានជើងមកដល់បណ្តាប្រទេសទាំងឡាយនៅអាស៊ីប៉ែកអាគ្នេយ៍។ ចំណេះដឹងខាងព្រះពុទ្ធសាសនាបែបសិង្ហលៈមានភាពទូលំទូលាយ។ បើតាមឯកសារប្រវត្តិសាស្រ្តសីរីលង្កា ក្នុងពេលនេះប្រហែលជាមានព្រះរាជនីខ្មែរមួយព្រះអង្គបានទៅទស្សនកិច្ចនៅប្រទេសសីរីលង្កា ដើម្បីសិក្សាព្រះពុទ្ធសាសនាបែបសិង្ហលៈក្រោមការបង្ហាត់បង្រៀនរបស់ព្រះមហាថេរៈជនជាតិសិង្ហលៈ។
ព្រះពុទ្ធសាសនាបន្តការរីកដុះដាលក្នុងប្រទេសកម្ពុជាក្នុងសតវត្សន៍ទី១៣តែនៅមិនទាន់ក្លាយជានិកាយសាសនាធំជាងគេទេ។ បន្ទាប់មកនិកាយថេរវាទបានក្លាយជាសាសនារបស់រដ្ឋ។

ការផ្លាស់ប្តូររបស់ព្រះពុទ្ធសាសនា បានកើតឡើងដោយឥទ្ធិពលរបស់ថៃដែលបានជះឥទ្ធិពលនិងវាយដណ្តើមយកដែនដីភាគច្រើនរបស់ខ្មែរ។ ដូចគ្នាដែរឥទ្ធិពលរបស់ថៃ ព្រះពុទ្ធសាសនាបែបសិង្ហលៈក៏បានសាយភាយក្នុងកម្ពុជា។ ក្រោយមកអាទិទេពដំកល់ក្នុងប្រាសាទអង្គរវត្តត្រូវបានជំនួសដោយព្រះពុទ្ធបដិមា។ ព្រះពុទ្ធសាសនាបានក្លាយជាសាសនាចំបងមកដល់បច្ចុប្បន្ន សាសនាព្រាហ្មណ៍ហាក់បីដូចជាមិនអាចងើបមុខឡើងវិញបានទៀតឡើយ។

នៅសតវត្សន៍ទី១៦ *ព្រះបាទអង្គច័ន្ទ* (គ.ស.១៥១៦-១៥៦៦) ជាព្រះញាតិ *ព្រះបាទធម្មរាជា* ជាពុទ្ធមាមកៈសំខាន់។ ព្រះអង្គបានកសាងវត្តពេញរាជធានី និងទីសក្ការៈសំខាន់ៗមានចេតិយ៍ជាដើមទូទាំងប្រទេស។ ដើម្បីអោយព្រះពុទ្ធសាសនាមានប្រជាប្រិយភាពខ្លាំង *ព្រះអង្គសត្ថា* (គ.ស.១៥៧៦-១៥៩៤)ជាព្រះរាជបុត្រនិងរាជទាយាទ *ព្រះបាទបរមរាជា* បានជួសជុលប្រាសាទអង្គរវត្តដ៏អស្ចារ្យ។

សម័យអាណានិគមបារាំង (គ.ស.១៨៦៣-១៩៥៤) ព្រះពុទ្ធសាសនាហាក់បីដូចគាំងស្ទះតែក៏មានអ្នកប្រាជ្ញខ្មែរជាច្រើនផុសចេញឡើងដែរ ដូចជាសម្តេចល្វីឯម សម្តេចជួនណាត សម្តេចហួត តាត ប៉ាង ខាត់


រៀបរៀងដោយ ព្រះភិក្ខុវោទានោ សេង សុភ័ណ (បរិញ្ញាប័ត្រទស្សនវិជ្ជា)

ជាដើម។ ទើបមកដល់សម័យសង្គមរាស្ត្រនិយមព្រះពុទ្ធសាសនាត្រូវបានលើកតំកើងជាសាសនារបស់រដ្ឋក្រោមព្រះរាជករណីកិច្ចដ៏ជ្រះថ្លារបស់សម្តេចព្រះនរោត្តមសីហនុ។ ការដឹកនាំប្រទេសភាគច្រើនយកលំនាំតាមទ្រឹស្តីព្រះពុទ្ធសាសនា។ លុះដល់សម័យប៉ុលពត (គ.ស.១៩៧៥-៧៩) ព្រះពុទ្ធសាសនាត្រូវបានគេបំផ្លាញចោលទាំងស្ថាប័ន ប៉ុន្តែចំពោះតែទិដ្ឋភាពខាងក្រៅតែប៉ុណ្ណោះ ព្រោះទឹកចិត្តខាងក្នុងប្រជាជនខ្មែរនៅតែគោរពព្រះពុទ្ធសាសនាដដែល ដែលគេអាចពិសោធន៍បាននៅពេលដែលគេឃើញវត្តវាអារាមដុះដូចផ្សិតក្រោយពីសម័យប៉ុលពតត្រូវបានដួលរលំ។

បច្ចុប្បន្នព្រះពុទ្ធសាសនាបានកំពុងលូតលាស់យ៉ាងសន្សឹមៗក្រោមបាវចនាជាតិ សាសនា ព្រះមហាក្សត្រ ហើយព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋក្នុងមាត្រាទី ៤៣ ដែលចែងថា

" *ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។ សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងលក្ខខណ្ឌ ដែលមិន ប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។ ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ"* ។

ហើយក្នុងមាត្រាទី៦៨ រដ្ឋនឹងត្រូវតែទទួលស្គាល់និងគាំទ្រដល់ការសិក្សារបស់ព្រះភិក្ខុសង្ឃដែលហៅថាពុទ្ធិកសិក្សា ដោយចែងយ៉ាងច្បាស់ក្នុងរដ្ឋធម្មនុញ្ញថា

"រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សា នៅសាលារៀនសាធារណៈ សម្រាប់ប្រជាពលរដ្ឋគ្រប់រូប ដោយឥតបង់ថ្លៃ ។ ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិច ៩ ឆ្នាំ។ រដ្ឋជួយផ្សព្វផ្សាយ និងលើកតម្កើងសាលាបាលី និងពុទ្ធិកសិក្សា" ។

តាមរយៈច្បាប់រដ្ឋធម្មនុញ្ញនិងការអភិវឌ្ឍន៍ជាបណ្តើរៗរបស់ព្រះពុទ្ធសាសនាក្រោមការជួយជ្រោមជ្រែងយ៉ាងម៉ឺងម៉ាត់ពីស្ថាប័នសង្ឃ ក្រសួងធម្មការនិងសាសនា ក្រសួងអប់រំនិងពុទ្ធិកសិក្សា អង្គការក្រៅរដ្ឋាភិបាលផ្សេងៗ អ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាល្បីៗ ព្រមទាំងពុទ្ធបរិស័ទទាំងអស់ ទាំងក្នុងប្រទេសនិងក្រៅប្រទេសជួយគ្នាជ្រោមជ្រែងលើកស្ទួយទាំងកំលាំងកាយ កំលាំងចិត្ត និងកំលាំងបញ្ញា ដើម្បីអោយព្រះពុទ្ធសាសនារីកចំរើន។ ការរីកចំរើនរបស់ព្រះពុទ្ធសាសនានេះស្ថិតក្រោមសម្មាទិដ្ឋិដែលថា " *កាលណាព្រះពុទ្ធសាសនារីកចំរើន ប្រទេសកម្ពុជានិងពិភពលោកមានសុខសន្តិភាព ហើយសុខសន្តិភាពនេះមិនមែនមានត្រឹមតែបច្ចុប្បន្នកាលនេះទេគឺមានរហូតដល់អនាគតកាល និងមានជាអចិន្ត្រៃយ៍ឬបរមសុខបគឺព្រះនិព្វាន។ ព្រះពុទ្ធសាសនារីកចំរើនមានន័យថាប្រទេសកម្ពុជានឹងមានគុណភាពជីវិតការរស់នៅកាន់តែខ្ពស់ឡើង មានន័យថាសេដ្ឋកិច្ចក៏រីកចំរើន ប្រព័ន្ធច្បាប់ក៏ត្រូវគេគោរព អ្នកដឹកនាំនឹងតំកល់ខ្លួននៅក្នុងគុណធម៌ ប្រជាជនដែលជាអ្នកតាមក៏តំកល់ខ្លួនក្នុងគុណធម៌និងមានទំនួលខុសត្រូវតាមកាតព្វកិច្ច ករណីយកិច្ចខ្លួនឯង"* ។